ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...........សហវ.............

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០១៦

**ជម្រាបជូន**

- **ឯកឧត្តមអគ្គលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
- **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានថវិកា**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ**

**កម្មវត្ថុ:** ផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ២០១៦ ។

**យោង:**
- ព្រះរាជក្រមលេខ នស/រកម/ ០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- ព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥
- អនុក្រឹត្យលេខ ៤៨៨ អនក្រ/បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ ៤០ / អនក្រ / បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ
- ប្រកាសលេខ ១៥៤៧ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លិខិតលេខ ២៣២៩ សហវ.អសក ចុះថ្ងៃទី ២១ ខែមេសាឆ្នាំ ២០១៤ ស្តីពីផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុង ២០១៤-២០១៦
- ផ្អែកតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៨៩
Phone : 855-23-724 664 Fax : 855-23-427 789

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមជ្រាបថា ដើម្បីជំរុញឱ្យថវិកាក្លាយជាឧបករណ៍គោល-នយោបាយដ៏មានប្រសិទ្ធភាព ធានាសម្រេចបាននូវគោលបំណងទាំងឡាយ បានកំណត់នៅក្នុងផែនការ កម្មវិធី និង យុទ្ធសាស្ត្រជាតិនានា ជាពិសេស **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទីបីរបស់រាជរដ្ឋាភិបាល ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព** និង**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាននិងកំពុង បន្តកែទម្រង់យ៉ាងមុតស្រួចលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលបច្ចុប្បន្នកំពុងឈានចូលដំណាក់កាលទីបី គឺ "**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**"។ គន្លឹះនៃជោគជ័យនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ គឺអាស្រ័យ នឹងប្រព័ន្ធទាំងឡាយដែលបានបង្កើត កែលម្អ និងកំពុងរៀបចំថ្មីត្រូវបានធានាគុណភាពរឹងមាំ និងប្រសិទ្ធភាពខ្ពស់ក្នុង ការប្រើប្រាស់។

ស្ថិតក្នុងបរិការណ៍នេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានណែនាំឱ្យអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង រៀបចំផែនការ សវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ២០១៦ ផ្អែកលើផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុង ២០១៤-២០១៦ ដោយកែតម្រូវ តម្រង់ និងផ្តោតបន្ថែមលើគោលដៅសវនកម្មឱ្យឆ្លើយតបជាមួយ និងគាំទ្រដល់តម្រូវការនៃការវិវត្តន៍ថ្មីៗនេះ ពិសេសនៅក្នុង វិស័យបញ្ជិកាគណនេយ្យ ពន្ធដារ គយនិងរដ្ឋាករ ចំណូលមិនមែនសារពើពន្ធ លទ្ធកម្មសាធារណៈ ការផ្តល់សេវា សាធារណៈ ការកសាងយុទ្ធសាស្ត្រថវិកា ការអនុវត្តនិងវាយតម្លៃថវិកាកម្មវិធី ការលប់បំបាត់មន្ត្រីខ្មោច ការវិភាគមុខងារ ការលើកទឹកចិត្ត អភិបាលកិច្ចល្អ ការដាក់ឱ្យដំណើរការនូវប្រព័ន្ធ FMIS ជាពិសេសការពង្រឹងការប្រើប្រាស់បច្ចេក-វិទ្យាព័ត៌មាន និងការផ្លាស់ប្តូរពាក់ព័ន្ធបញ្ហាសំខាន់ៗមួយចំនួន ក្នុងគោលបំណងជួយសម្រាលបន្ទុក និងការលំបាករបស់ ប្រជាពលរដ្ឋទូទាំងប្រទេស ដែលជាការណែនាំនិងការសម្រេចដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ ទន្ទឹមនឹងនេះ ការកែលម្អក៏ត្រូវបានធ្វើនៅលើទិដ្ឋភាព បច្ចេកទេសសវនកម្មផងដែរ ដោយកំណត់ឱ្យចាប់ផ្តើមបញ្ចូលនូវធាតុខ្លះនៃសវនកម្មលើសមិទ្ធកម្ម។

ជាលទ្ធផល ផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ២០១៦ (ដូចមានភ្ជាប់មកជាមួយ) បានគ្របដណ្តប់ទៅលើកិច្ច ដំណើរការសំខាន់ៗ មុខសញ្ញា និងចំណុចយកចិត្តទុកដាក់ជាអាទិភាពរបស់រាជរដ្ឋាភិបាល នៅតាមគណៈកម្មាធិការ អគ្គលេខាធិការដ្ឋាន និងអគ្គនាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំនួន ០៨ និងអង្គភាពតាមរាជធានី-ខេត្ត ចំនួន ២៥។

ដូច្នេះ ដើម្បីសម្រេចផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ២០១៦ ក្នុងគោលបំណង និងវិសាលភាពខាងលើប្រកប ដោយលទ្ធផលល្អប្រសើរ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវបំពេញភារកិច្ចប្រកបដោយជំនាញ ស្មោះត្រង់ ឯករាជ្យ ស្របតាមស្តង់ដា និងក្រមសីលធម៌វិជ្ជាជីវៈនៃសវនករផ្ទៃក្នុង និងមានសិទ្ធិចូលដល់ប្រព័ន្ធ មន្ត្រី បញ្ជិកា ស្ថិតិ ទ្រព្យសម្បត្តិ និងផ្ទៀងផ្ទាត់ដល់គោលដៅជាក់ស្តែង ស្របតាមនីតិវិធីសវនកម្មស្តង់ដា។ របាយការណ៍សវនកម្មផ្ទៃក្នុងត្រូវគាំទ្រដោយ ភស្តុតាងជាក់លាក់ និងគ្រប់គ្រាន់ រួមទាំងការធ្វើតេស្តផ្ទៀងផ្ទាត់បន្ថែមនៅតាមគោលដៅពាក់ព័ន្ធ។ ទន្ទឹមនឹងនេះ សវនដ្ឋាន ទាំងអស់ត្រូវផ្តល់កិច្ចសហការជិតស្និទ្ធដល់សវនករ ជាមួយស្មារតីទទួលខុសត្រូវខ្ពស់។

ក្រៅពីការធ្វើសវនកម្មតាមផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ២០១៦ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងត្រូវចុះសវនកម្មតាមការសម្រេចដោយឡែករបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមការចង្អុរផ្ទាល់របស់រដ្ឋមន្ត្រី លើពាក្យបណ្ដឹងនិងសំណូមពររបស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ការចុះអនុវត្តសវនកម្មអាចប្រព្រឹត្តទៅដោយផ្ដល់ព័ត៌មានជាមុន និងមិនផ្ដល់ជាមុនតាមការចាំបាច់ ។ ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ក៏ត្រូវចុះតាមដានវឌ្ឍនភាពនៃការកែលម្អតាមអនុសាសន៍ នៅតាមគោលដៅមួយចំនួនដែលនឹងត្រូវធ្វើឡើងតាមអាទិភាព ក្នុងរយៈពេលយ៉ាងយូរ ៦ ខែ ក្រោយសវនកម្មនីមួយៗបានបញ្ចប់ ។

អាស្រ័យហេតុនេះ សូមឯកឧត្តមជ្រាប និងចូលរួមសហការអនុវត្តផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ២០១៦ នេះឱ្យសម្រេចបានជោគជ័យប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

សូមឯកឧត្តមទទួលនូវការរាប់អានពីខ្ញុំ ៚

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

<u>ចម្លងជូនៈ</u>

- អាជ្ញាធរសវនកម្មជាតិ “ដើម្បីជូនជ្រាប”
- សវនដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ “ដើម្បីសហការអនុវត្ត”
- ឯកសារ-កាលប្បវត្តិ